ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 28 / 11 / 2014
ម៉ោង (Time/Heure): 9:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

លេខ / N°: A67

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**

**សំណុំរឿងព្រហ្មទណ្ឌ**
**Criminal Case File /Dossier pénal**
**លេខ/No:003/07-09-2009-ECCC-OCIJ**

# ដីកាកោះហៅមេធាវី
# Summons of Lawyer
# Convocation d'avocat

ខ្ញុំ **Mark B. Harmon** សហចៅក្រមស៊ើបអង្កេតអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**បានឃើញ** ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤(“ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក”)។

**បានឃើញ**វិធាន ២១, ៤១, ៤៥, ៥៥, ៥៧ និង៧២ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“វិធានផ្ទៃក្នុង”)។

**បានឃើញ** *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ របស់សហព្រះរាជអាជ្ញាទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជា* ដាក់នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩[1]។

**បានឃើញ** *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣* ដាក់នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤(”ដីកាសន្និដ្ឋានបញ្ជូនឲ្យស៊ើបសួរបន្ថែម”[2]។

---

[1]សំណុំរឿង ០០៣ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២របស់សហព្រះរាជអាជ្ញា ទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជា* ដាក់នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩។

**បានឃើញ** កិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់អំពីការរំលោភបំពាន**ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** និង**ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩** ជាបទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៣(ថ្មី), ៥, ៦, ២៩ និង ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា៥០០, ៥០១, ៥០៣, ៥០៥, ៥០៦, ៥០៧ និង ៥០៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

**បានឃើញ**កំណត់ហេតុនៃករណីខ្វែងយោបល់គ្នា ចុះបញ្ជីនៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ និងថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាម ២០១៣។

**បានឃើញ**កំណត់ហេតុនៃករណីខ្វែងយោបល់គ្នា ចុះបញ្ជីនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤។

**បានឃើញ**ថា ខ្ញុំបានចេញដីកាកោះហៅមាស មុត ឲ្យមកបង្ហាញខ្លួននៅចំពោះមុខខ្ញុំ នៅ អ.វ.ត.ក នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ ២០១៤ ម៉ោង១រសៀល សម្រាប់ការបង្ហាញខ្លួនលើកដំបូង[3]។

អាស្រ័យហេតុនេះ **ស្នើ** លោក អាង ឧត្តម និងលោក Michael G. Karnavas ដែលអង្គបុរេជំនុំជម្រះបានទទួលស្គាល់ជាសហមេធាវីតំណាងមាស មុត នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៤[4] ហើយមានការិយាល័យនៅ អ.វ.ត.ក

**ឲ្យមកបង្ហាញខ្លួននៅចំពោះមុខខ្ញុំ នៅ អ.វ.ត.ក មានទីតាំងនៅផ្លូវជាតិលេខ ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ**

**នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ ២០១៤ ម៉ោង១រសៀល**

**ដើម្បីចូលរួមការបង្ហាញខ្លួនលើកដំបូងរបស់មាស មុត។**

---

[2]សំណុំរឿង ០០៣ ឯកសារ D120 *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣* ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤។

[3]សំណុំរឿង ០០៣ ឯកសារ A66 *ដីកាកោះហៅមាស មុត ឲ្យបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ* ២០១៤។

[4]សំណុំរឿង០០៣ ឯកសារD56/19/36 *សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិច្រានចោលការតែងតាំងអាង ឧត្តម និងMichael KARNAVAS ជាសហមេធាវី* ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤។ សំណុំរឿង០០៣ ឯកសារD56/19/38 *សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់មាស មុត ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលបដិសេធការតែងតាំងលោកអាង ឧត្តម និងលោក Michael KARNAVAS មិនឲ្យធ្វើជាសហមេធាវីរបស់គាត់* ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤។

០០៣/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស **លេខ៖** A67

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ២០១៤

**ចៅក្រម Mark B. Harmon**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

International Co- Investigating Judge

Co-juge d'instruction International